រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

ព្រឹត្តិប័ត្រ

លេខ ១០ ខែឧសភា ឆ្នាំ២០០៨

# អនុសញ្ញារួម ផ្តល់អត្ថប្រយោជន៍ដល់គ្រប់ភាគីទាំងអស់នៅក្នុងឧស្សាហកម្មកាត់ដេរ

នៅក្នុងឆ្នាំ ២០០៧ ប្រទេសកម្ពុជាបានប្រារព្ធខួបលើកទី ១០ នៃការបង្កើតច្បាប់ស្តីពីការងាររបស់ខ្លួន។ បើយើងត្រលប់មើលកាលពីឆ្នាំ ១៩៩៧ វិញ ពេលនោះឧស្សាហកម្មកាត់ដេរមានស្ថានភាពខុសគ្នាស្រឡះពីស្ថានភាពនាពេលបច្ចុប្បន្ននេះ។ កាលនោះ មាននិយោជកតិចតួចតែប៉ុណ្ណោះ ហើយគ្មានសកម្មភាពសហជីពទាល់តែសោះ។ ស្ថានភាពកាលពីពេលនោះគឺអាក្រក់ខ្លាំងណាស់: «កម្មករនិយោជិតមើលឃើញតែការបង្ខិតបង្ខំ ដោយសារតែមិនទាន់មានតំណាងសហជីព» នេះបើតាមសំដីលោក អាត់ ធន់ ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា។

អ្វីៗបានផ្លាស់ប្តូរយ៉ាងច្រើនអនេក ចាប់តាំងពីពេលនោះមក។ ប្រទេសកម្ពុជាមានការរីកចំរើនផ្នែកសេដ្ឋកិច្ចយ៉ាងសុះសាយ ហើយបានវិលត្រលប់មករកបរិយាកាសមួយដែលមានស្ថិរភាព និងសន្តិសុខជាងមុន។ ឧស្សាហកម្មកាត់ដេរបានពង្រីកខ្លួនយ៉ាងធំធេង ហើយកម្មករនិយោជិតបំរើការងារក្នុងវិស័យនេះកាន់តែមានចំនួនច្រើនឡើង។ រួមជាមួយនេះផងដែរ សហជីពមានការរីកចំរើនគួរអោយកត់សំគាល់។ ប៉ុន្តែ រហូតមកទល់នឹងពេលបច្ចុប្បន្ននេះជារឿយៗ អ្នកគ្រប់គ្រងមិនមានបទពិសោធន៍គ្រប់គ្រាន់ ក្នុងការដោះស្រាយបញ្ហាដែលកើតឡើងនៅក្នុងកន្លែងធ្វើការតាមរយៈសហជីពឡើយ។ សហជីពដ៏ក្មេងខ្ចីទាំងនេះនៅខ្វះខាតសមត្ថភាព ដើម្បីដោះស្រាយវិវាទ ក្រៅពីការប្រើប្រាស់មធ្យោបាយធ្វើកូដកម្ម «ភ្លាមៗ ដោយមិនបានអនុលោមទៅតាមនីតិវិធីដែលមាន»។ នៅក្នុងឆ្នាំ ២០០៧ មានកូដកម្មចំនួន ៨០ ករណីបានកើតមានឡើង ដែលស្មើនឹងការខាតបង់ថ្ងៃធ្វើការចំនួន ២៩០ ០០០ ថ្ងៃ ឬ ជិតមួយថ្ងៃសម្រាប់កម្មករនិយោជិតម្នាក់ក្នុងរយៈពេលមួយឆ្នាំ។ ស្ថានភាពបែបនេះធ្វើអោយមានការខាតបង់ដល់ផលិតភាព ហើយវាក៏មានន័យផងដែរថា ភាពមិនប្រាកដប្រជាបង្កឡើងដោយសារកូដកម្ម បង្កើតអោយមានហានីភ័យកាន់តែខ្ពស់ជាងមុនសម្រាប់អ្នកបញ្ជាទិញ។ វាគំរាមកំហែងដល់បរិយាកាសវិនិយោគ និងសក្តានុពលកំណើនសេដ្ឋកិច្ចសម្រាប់ប្រទេសជាតិទាំងមូល។

នាពេលបច្ចុប្បន្ន ស្ថានភាពបែបនេះមានការផ្លាស់ប្តូរ។ លោក អាត់ ធន់ មានប្រសាសន៍ថា: «ឥលូវនេះ និយោជក រដ្ឋាភិបាល និងកម្មករនិយោជិតសុទ្ធតែទាមទារអោយមានការចរចារ មិនមែនទាមទារវិវាទនោះទេ»។ អង្គការពលកម្មអន្តរជាតិ (ILO) កំពុងចាត់ទុកអនុសញ្ញារួម (CBAs) ជាមធ្យោបាយគត់មត់បំផុត ដែលផ្តល់អត្ថប្រយោជន៍ដល់គ្នាទៅវិញទៅមក ដើម្បីបង្ការវិវាទមិនអោយកើតមានឡើង និងដោះស្រាយបញ្ហារបស់កម្មករ និយោជិតផង និងរបស់និយោជកផង។

អនុសញ្ញារួម ខុសប្លែកពីប្រភេទការចរចារដែលសហជីព និងអ្នកគ្រប់គ្រងធ្លាប់មាន ដែលជាធម្មតាការចរចារទាំងនេះគឺដើម្បីដោះស្រាយវិវាទដែលកើតឡើងភ្លាមៗ និងដើម្បីដោះស្រាយកូដកម្មដែលកើតឡើងភ្លាមៗ។ ពីវិវាទមួយ ទៅវិវាទមួយទៀត អ្នកគ្រប់គ្រង និងសហជីពពុំមានចក្ខុវិស័យរយៈពេលវែង ឬ មធ្យោបាយដើម្បីដោះស្រាយគ្រប់បញ្ហាទាំងអស់ដែលកើតមានឡើងអោយបានមធ្យ័ត សំដៅបង្ការមិនអោយវិវាទកើតឡើងតាំងពីប្រភពដំបូងនោះឡើយ។ ជាការពិត អនុសញ្ញារួម គឺជាមធ្យោបាយដើម្បីសំរេចគោលដៅនេះ។

ដើម្បីលើកកំពស់អោយមានការប្រើប្រាស់អនុសញ្ញារួមអោយបានកាន់តែទូលំទូលាយ អង្គការពលកម្មអន្តរជាតិជាមួយនឹងបណ្តាដៃគូរបស់ខ្លួន កំពុងធ្វើការបណ្តុះបណ្តាលរយៈពេលខ្លីៗ និងលើកកំពស់ការយល់ដឹងអំពីអនុសញ្ញារួមសម្រាប់អ្នកគ្រប់គ្រង និងសហជីពទាំងនៅកំរិតសហព័ន្ធ និងនៅកំរិតសហគ្រាស ដោយផ្តោតជាសំខាន់លើសហជីពដែលមានភាពជាតំណាងបំផុត (MRS)។

សហជីពដែលមានភាពជាតំណាងបំផុត គឺជាសហជីពដែលមានសមាជិកជាកម្មករនិយោជិតចំនួន ៥១% នៃកម្មករ និយោជិតសរុបនៅក្នុងរោងចក្រ ហើយមានសមាជិកចំនួន ៣៣% បង់វិភាគទានសមាជិកភាព។ សហជីពដាក់ពាក្យទៅកាន់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីសុំវិញ្ញាបនប័ត្រភាពជាតំណាងបំផុត។ ប្រសិនបើពាក្យសុំនេះមានបញ្ហា នោះសហជីពដែលដាក់ពាក្យសុំ អាចស្នើសុំអោយមានការបោះឆ្នោត។ នៅពេលដែលទទួលបានវិញ្ញាបនប័ត្របញ្ជាក់ហើយ ភាពជាតំណាងបំផុតនឹងមានរយៈពេលកំណត់ចំនួនពីរឆ្នាំ ហើយអាចបន្តដោយគ្មានកំណត់ បន្ទាប់ពីរយៈពេលពីរឆ្នាំនេះរហូតទាល់តែមានការប្រកួតប្រជែងពីសហជីពមួយទៀត។ *សូមអានតទៅទំព័រទី ២*

# ស្នាដៃដែលទទួលបានជោគជ័យនៅក្នុងការប្រកួតប្រជែង "ខ្ញុំមានតំលៃ" នឹងចូលរួមនៅក្នុងពិពរណ៌ទេសចរណ៍



ម៉ូដសំលៀកបំពាក់សម្រាប់វគ្គផ្តាច់ព្រ័តទាំង ១០ ឈុត នៅលើឆាក

យុទ្ធនាការ និងការប្រកួតប្រជែងរចនាម៉ូដសំលៀកបំពាក់ និងតែងបទចំរៀងក្រោមប្រធានបទ «ខ្ញុំមានតំលៃ» ដែលបានចាប់ផ្តើមក្នុងខែសីហា បានដល់ទីបញ្ចប់នៅថ្ងៃទី ១៦ ធ្នូ ២០០៧។

យុទ្ធនាការនេះ មានគោលបំណងបង្កើតនូវតំលៃផ្ទាល់ខ្លួន និងបង្ហាញពីទេពកោសល្យរបស់កម្មករនិយោជិតរោងចក្រ ក៏ដូចជាផ្សព្វផ្សាយនូវសារសង្គមវិជ្ជមានទៅកាន់បេក្ខជន បេក្ខនារីដែលចូលរួមក្នុងការប្រកួតប្រជែង និងប្រជាជនទាំងអស់។ គោលដៅចម្បង គឺដើម្បីផ្សព្វផ្សាយជាសាធារណៈ និងផ្តល់គុណតំលៃដល់ការចូលរួមចំណែករបស់កម្មករនិយោជិតរោងចក្រកាត់ដេរ ចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

កម្មករនិយោជិតតាមរោងចក្រកាត់ដេរភាគច្រើនជាស្ត្រីក្មេងៗ មិនសូវទទួលបានការអប់រំ និងមកពីសហគមន៍ជនបទក្រីក្រ។ វិញ្ញាសារចនាម៉ូដ និងតែងបទចំរៀង (ក្រោមប្រធានបទ ជីវិត និងការងារ) ត្រូវបានចាត់ទុកថាជាមូលបទសំខាន់ៗ ដែលកម្មករនិយោជិតរោងចក្រកាត់ដេរអាចចូលរួម ដើម្បីបញ្ជាក់បង្ហាញពីសាវតា និងទេពកោសល្យផ្ទាល់ខ្លួនរបស់ពួកគេ។

វគ្គប្រកួតផ្តាច់ព្រ័ត្រ បានប្រារព្ធធ្វើឡើងក្រោមអធិបតីភាពរបស់លោកជំទាវវេជ្ជបណ្ឌិត អ៊ឹង កន្ធាផាវី រដ្ឋមន្ត្រីក្រសួង កិច្ចការនារី និងឯកឧត្តម អ៊ូស្មាន់ ហាស្សាន់ រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ព្រឹត្តិការណ៍នេះត្រូវបានចាក់ផ្សាយតាមកញ្ចក់ទូរទស្សន៍ ដើម្បីអាចបញ្ជូនព័ត៌មានទៅដល់ទស្សនិកជនអោយបានច្រើននាក់បំផុតតាមដែលអាចធ្វើទៅបាន។

ក្នុងជុំដំបូង មានមនុស្សជាង ៤០០ នាក់ដែលកំពុងធ្វើការងារនៅក្នុងឧស្សាហកម្មកាត់ដេរ បានចូលរួមនៅក្នុងការប្រកួតប្រជែងនេះ (អ្នករចនាម៉ូដសំលៀកបំពាក់មានចំនួន ២៣០ នាក់ និងអ្នកនិពន្ធបទចំរៀងមានចំនួន ១៧០ នាក់)។ បន្ទាប់ពីជម្រុះរួចមក មានអ្នករចនាម៉ូដសំលៀកបំពាក់ចំនួន ១០ នាក់ និងអ្នកនិពន្ធបទចំរៀងចំនួន ៥ នាក់ ត្រូវបានជ្រើសរើសសម្រាប់ការប្រកួតវគ្គផ្តាច់ព្រ័ត្រ។ អ្នកទទួលជ័យលាភីចុងក្រោយ គឺត្រូវបានជ្រើសរើសចេញពីអ្នកប្រកួតវគ្គផ្តាច់ព្រ័ត្រទាំងនេះនៅថ្ងៃទី ១៦ ធ្នូ ដោយគណៈវិនិច្ឆ័យចំនួនពីរក្រុម ដែលមានសមាសភាពជាតំណាងរដ្ឋាភិបាល រោងចក្រ សហជីព និងអ្នកបញ្ជាទិញ (Gap និងH&M) រួមជាមួយនឹងអ្នកឯកទេសខាងម៉ូដសំលៀកបំពាក់ និងចំរៀងផងដែរ។

ម៉ូដសំលៀកបំពាក់ជាផ្លូវការត្រូវបានបង្កើតចេញជារូបរាង និងស្លៀកបង្ហាញ ដើម្បីអោយគណៈវិនិច្ឆ័យធ្វើការសំរេចចិត្ត។ ជ័យលាភីទីមួយ គឺបានទៅលើកញ្ញា សែម សុខនី អាយុ ១៨ ឆ្នាំ ដែលរចនាម៉ូដរ៉ូបពាក់ពេលរសៀលពណ៌ខៀវចាំងរឹមៗបើកក។ ជ័យលាភីទីពីរ បានទៅលើអ្នកស្រី ប៉ុល គន្ធា អាយុ ៣៥ ឆ្នាំ និងជ័យលាភីទីបី បានទៅលើអ្នកស្រី គឹម យុនគង្គា អាយុ ២៤ ឆ្នាំ។

កញ្ញា សែម សុខនី មកពីខេត្តកណ្តាល ហើយបានបញ្ចប់ការសិក្សានៅថ្នាក់ទី ៩។ នាងបានមកធ្វើការនៅក្នុងរោងចក្រកាត់ដេរ ម៉ាក់លីន អស់រយៈពេលពីរឆ្នាំមកហើយ។ នាងនិយាយថា នាងបានចំណាយពេលប្រហែលជា ៧ ថ្ងៃ ដើម្បីរចនាម៉ូដសំលៀកបំពាក់របស់នាង។ នាងបន្តទៀតថា នាងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង មិននឹកស្មានថានាងបានចូលដល់ជុំផ្តាច់ព្រ័ត្រនេះសោះ។ នៅពេលនាងស្តាប់ឮព័ត៌មាននេះ នាងមិនជឿឡើយ ហើយនាងស្ទើតែមិនបានចូលរួមទស្សនានៅក្នុងវគ្គផ្តាច់ព្រ័ត្រ។ ជាសំណាងល្អ នាងបានទៅចូលរួម ហើយលទ្ធផលចុងក្រោយ គឺអស្ចារ្យយ៉ាងខ្លាំង ដូចដែលនាងនិយាយដោយខ្លួនឯងថា: «ខ្ញុំស្ទើរតែហោះនៅលើឆាកទៅហើយ នៅពេលដែលលទ្ធផលបានប្រកាសចេញមក»។ ឥលូវនេះ នាងមានចិត្តសប្បាយរីករាយ និងមានមោទនភាពយ៉ាងខ្លាំង ហើយចង់បន្តរចនាម៉ូដជាបន្តទៅទៀត។ នាងក៏ចង់សន្សំប្រាក់រង្វាន់ខ្លះ ដើម្បីរៀនភាសាចិនផងដែរ។ សែម សុខនី ចង់ក្លាយជាអ្នកបកប្រែ។ នាងនិយាយថា នាងនឹងអាចផ្គត់ផ្គង់គ្រួសារនាងបានប្រសើរជាងមុន ដើម្បីអោយពួកគេបានបញ្ចប់ការសិក្សា។

ចំពោះវិញ្ញាសាតែងបទចំរៀងវិញ សិល្បករអាជីពបានច្រៀងចំរៀងដែលនិពន្ធដោយអ្នកជាប់នៅក្នុងវគ្គប្រកួតផ្តាច់ព្រ័ត្រទាំង ៥ រូប។ កញ្ញា តួច ស្រីនិត អាយុ ២៤ ឆ្នាំ បានទទួលជ័យលាភីទីមួយ ជាមួយនឹងបទចំរៀងរបស់នាងដែលរៀបរាប់ពីជីវិតរបស់នាងនៅទីជនបទ និងការងាររបស់នាងក្នុងរោងចក្រកាត់ដេរនៅភ្នំពេញ។ ជ័យលាភីទីពីរ បានទៅលើលោក រាជ សារ៉ាត់ អាយុ ២៩ ឆ្នាំ និងជ័យលាភីទីបី បានលើលោក ពេញ រដ្ឋា អាយុ ២៨ ឆ្នាំ។

កញ្ញា តួច ស្រីនិត បំរើការងារនៅក្នុងរោងចក្រកាត់ដេរ ហុងវ៉ា ហើយបានចំណាយពេលទំនេររបស់នាងនិពន្ធរឿង កំណាព្យ និងបទចំរៀង។ សុបិន្តចង់ក្លាយជាអ្នកនិពន្ធរបស់នាង អាចនឹងមានឱកាសក្លាយជាការពិត។ នាងចូលធ្វើការតាំងពីអាយុ ១៤ ឆ្នាំ ហើយក្នុងរយៈពេល ៧ ឆ្នាំចុងក្រោយនេះ នាងធ្វើការនៅក្នុងរោងចក្រហុងវ៉ា។

តួច ស្រីនិត បានដឹងពីការប្រកួតប្រជែងនេះតាមរយៈការិយាល័យរដ្ឋបាលរបស់នាង។ នាងបានសរសេរបទចំរៀងមួយ រៀបរាប់ពីការចាកចេញពីទីជនបទមកធ្វើការនៅក្នុងរោងចក្រ។ ការឈ្នះជ័យលាភីនេះ គឺជាការភ្ញាក់ផ្អើលមួយយ៉ាងធំ: «ខ្ញុំមិនដែលគិតថា ខ្ញុំនឹងឈ្នះការប្រកួតប្រជែងនេះឡើយ។ ខ្ញុំគ្រាន់តែចង់ស្តាប់បទចំរៀង ដែលខ្ញុំសរសេរដោយខ្លួនឯងប៉ុណ្ណោះ ប៉ុណ្ណឹងគឺវាគ្រប់គ្រាន់ហើយសម្រាប់ខ្ញុំ»។ នាងមានមោទនភាព ដែលបានឈ្នះការប្រកួតនេះ ដោយសារតែសមត្ថភាពផ្ទាល់ខ្លួនរបស់នាង ហើយនាងសង្ឃឹមថានឹងអាចរៀនភាសាអង់គ្លេស ហើយបន្តការនិពន្ធនេះទៀតនាពេលអនាគត។

*សូមអានតទៅទំព័រទី ៣*

## ផ្នែកខាងក្នុង

វេទិកាអ្នកបញ្ជាទិញរបស់គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* រៀបចំឡើងនៅទីក្រុងហុងកុង
ប្រាក់បន្ថែមចំនួន ៦ ដុល្លាក្នុងមួយខែ ត្រូវបានផ្តល់ទៅអោយកម្មករនិយោជិតទាំងអស់នៅក្នុងឧស្សាហកម្មកាត់ដេរ
អ្នកផ្តល់សេវាបណ្តុះបណ្តាលធ្វើការងារដើម្បីបង្កើនផលិតភាព និងកែលំអទំនាក់ទំនងនៅកន្លែងធ្វើការ

ILO

# វេទិកាអ្នកបញ្ជាទិញរបស់គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា រៀបចំឡើងនៅទីក្រុងហុងកុង

វេទិកាអ្នកបញ្ជាទិញលើកទីមួយ នៃវេទិកាអ្នកបញ្ជាទិញទាំងពីរសម្រាប់ឆ្នាំ ២០០៨ ត្រូវបានរៀបចំឡើងនៅទីក្រុង ហុងកុង កាលពីថ្ងៃទី ២៧ និង ២៨ ខែ កុម្ភៈ។ កិច្ចប្រជុំនេះធ្វើការពិភាក្សាលើការផ្តោតសំខាន់ និងយុទ្ធសាស្ត្រនាពេលអនាគត របស់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* (BFC) នៃអង្គការពលកម្មអន្តរជាតិ ក៏ដូចជាបញ្ហានានារបស់ឧស្សាហកម្មកាត់ដេរ ដូចជាសមត្ថភាពប្រកួតប្រជែងផលិតភាព និងទំនាក់ទំនងវិជ្ជាជីវៈ។

វេទិកានេះត្រូវបានរៀបចំឡើងដោយស្ថាប័នអភិវឌ្ឍន៍វិស័យឯកជនទន្លេមេគង្គនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC-MPDF) រួមជាមួយនឹងគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* (BFC) ក្រោមការជួយសំរបសំរួលពីអាជីវកម្មសម្រាប់ការទទួលខុសត្រូវសង្គម(BSR) ដែលជាស្ថាប័នមួយធ្វើការខាងទទួលខុសត្រូវសង្គមដែលមានមូលដ្ឋាននៅទីក្រុងសានហ្វ្រាន់ស៊ីស្កូ។

នៅថ្ងៃទីមួយ ជាថ្ងៃដែលកំណត់អោយចូលបានតែចំពោះតំណាងរបស់អ្នកបញ្ជាទិញប៉ុណ្ណោះ ដែលត្រូវបានរៀបចំឡើងដោយក្រុមហ៊ុនវ៉លឌីសនី (Walt Disney)។ ព្រឹត្តិការណ៍ថ្ងៃទីពីរ ធ្វើឡើងនៅការិយាល័យរបស់ IFC ក្នុងទីក្រុងហុងកុង ដោយមានការចូលរួមពីតំណាងរបស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងបុគ្គលិករបស់ IFC ផងដែរ។

នៅក្នុងចំណោមអ្នកចូលរួមទាំងនោះ រួមមានអ្នកដែលពាក់ព័ន្ធទទួលបន្ទុកការអនុវត្តន៍ច្បាប់ និងអ្នកសំរេចលើការបញ្ជាទិញ ដែលជាតំណាងអោយអ្នកបញ្ជាទិញមកពីក្រុមហ៊ុនចំនួន ១៤ ដែលកំពុងធ្វើការងារជាមួយនឹងគំរោងនាពេលបច្ចុប្បន្ននេះ។ សរុបមានអ្នកបញ្ជាទិញចំនួន ២៩ ដែលកំពុងសហការជាមួយនឹងគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដែលក្នុងនោះមានអ្នកបញ្ជាទិញចំនួន១៤ កំពុងប្រើប្រាស់របាយការណ៍ពិនិត្យឃ្លាំមើលរបស់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*ទាំងស្រុង សម្រាប់តម្រូវការខាងការអនុវត្តន៍ច្បាប់របស់ពួកគេ។

នៅឯវេទិកាអ្នកបញ្ជាទិញអន្តរជាតិ ដែលរៀបចំឡើងក្នុងក្រុងភ្នំពេញកាលពីខែ កញ្ញា ឆ្នាំ ២០០៧ អ្នកបញ្ជាទិញសំលៀកបំពាក់នាំមុខគេចំនួន ២៣ បានបង្ហាញនូវការប្តេជ្ញាចិត្តបន្តបញ្ជាទិញពីរោងចក្រនៅក្នុងប្រទេសកម្ពុជាទៀត។ នៅទីក្រុងហុងកុង នៅពេលលើកយកបញ្ហានៃការធ្លាក់ចុះការបញ្ជាទិញនៅចុងឆ្នាំ ២០០៧ មកពិភាក្សា ជាថ្មីម្តងទៀត អ្នកបញ្ជាទិញបានបង្ហាញថា ពួកគេនឹងបន្តវិនិយោគ និងបញ្ជាទិញពីប្រទេសកម្ពុជាទៀត។

ឧត្តមភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជានៅក្នុងឧស្សាហកម្មកាត់ដេរសកល ក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ។ អ្នកបញ្ជាទិញគិតថា ក្រៅពីភាពរឹងមាំខាងការអនុលោមតាមច្បាប់ ប្រទេសកម្ពុជាមានសមត្ថភាពឆ្លើយតបនឹងការបញ្ជាទិញជាទ្រង់ទ្រាយធំ និងអាចរក្សាបាននូវភាពស្ថិតស្ថេរខាងគុណភាពផលិតផលៈ ពួកគេចាត់ទុកកត្តាទាំងនេះថា ជាកត្តាសំខាន់ៗ ដែលជាមូលហេតុធ្វើអោយក្រុមហ៊ុនរបស់ពួកគេបន្តដាក់ការបញ្ជាទិញទៀត។

បញ្ហាប្រឈមដែលបន្តនៅតែមានគឺ ផលិតភាពទាប កង្វះខាតសមាហរណកម្មតាមខ្សែរដេក និងបញ្ហាដែលពាក់ព័ន្ធនឹងការទទួលបានវត្ថុធាតុដើមដែលធ្វើអោយរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយរយៈពេលបញ្ជូនទំនិញ។

អ្នកបញ្ជាទិញក៏បានបង្ហាញផងដែរថា ពួកគេនឹងបន្តតាមដានយ៉ាងជិតស្និទ្ធលើការវិវត្តន៍នៃស្ថានភាពទំនាក់ទំនង វិជ្ជាជីវៈនៅក្នុងប្រទេសកម្ពុជា ហើយបានលើកទឹកចិត្តអោយរោងចក្ររបស់ពួកគេ បំពេញតួនាទីប្រកបដោយអត្ថន័យនៅក្នុងការបង្កើតអនុសញ្ញារួម និងដោះស្រាយគម្លាតនានាដែលមាននៅក្នុងលក្ខខណ្ឌការងារ។

នៅក្នុងការពិភាក្សាពីទស្សនៈវិស័យរបស់ឧស្សាហកម្ម តំណាងរបស់ GMAC បានបង្ហាញពីផ្នែកសំខាន់ៗ ដែលត្រូវធ្វើការកែលំអ ជាពិសេសលើការកាត់បន្ថយការិយាធិបតេយ្យ។ GMAC ក៏បានផ្តួចផ្តើមអោយមានជាសេវាបណ្តុះបណ្តាលជាច្រើនប្រភេទ ដែលមានគោលបំណងកសាងសមត្ថភាពរបស់ឧស្សាហកម្ម។ តំណាងរូបនេះបានលើកឡើងថា GMAC កំពុងបន្តធ្វើការងារលើសនិទានកម្ម និងកាត់បន្ថយតំលៃគយ ហើយតំលៃអគ្គិសនីដ៏សែនខ្ពស់ក៏ត្រូវបានចាត់ទុកថាជាឧបសគ្គដ៏ចម្បងមួយសម្រាប់ឧស្សាហកម្មផងដែរ។

អ្នកបញ្ជាទិញ មានចំណាប់អារម្មណ៍ចង់ឮបន្ថែមទៀតពីទស្សនៈវិស័យរបស់រោងចក្រ និងពីការងារដែលរដ្ឋាភិបាល និងវិស័យឯកជនបានធ្វើដើម្បីបង្កើតសមត្ថភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជា។ នៅក្នុងប្រទេសកម្ពុជាក៏មានការអំពាវនាវអោយមានការរៀនសូត្របន្ថែមទៀត ពីបរិយាកាសទំនាក់ទំនងវិជ្ជាជីវៈផងដែរ។ វេទិកាបានសំរេចថា ការពិភាក្សាលើបញ្ហាទាំងពីរនេះនឹងបន្តធ្វើឡើងនៅក្នុងវេទិកាអ្នកបញ្ជាទិញលើកទីពីរក្នុងឆ្នាំ ២០០៨ ដែលនឹងធ្វើឡើងក្នុងខែ កញ្ញា នៅទីក្រុងភ្នំពេញ។

## ប្រាក់បន្ថែមចំនួន ៦ ដុល្លាក្នុងមួយខែ ត្រូវបានផ្តល់ទៅអោយកម្មករនិយោជិតទាំងអស់នៅក្នុងឧស្សាហកម្មកាត់ដេរ

កាលពីថ្ងៃទី ៤ មេសា ២០០៨ កិច្ចប្រជុំមួយរបស់គណៈកម្មាធិការប្រឹក្សាការងារថ្នាក់ជាតិ (LAC) បានព្រមព្រៀងផ្តល់ប្រាក់បន្ថែមចំនួន ៦ ដុល្លាក្នុងមួយខែ ទៅអោយគ្រប់កម្មករនិយោជិតទាំងអស់ក្នុងវិស័យកាត់ដេរ ដែលចូលជាធរមានចាប់ពីខែមេសា តទៅ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយនឹងសហជីព និងរោងចក្រនៅក្នុងឧស្សាហកម្មនេះរួចមក។ ប្រាក់បន្ថែម ឬ ប្រាក់រង្វាន់នេះ មិនចាត់ទុកថាជាផ្នែកមួយនៃប្រាក់ឈ្នួលអប្បបរមានោះទេ។ ការព្រមព្រៀងនេះបញ្ចៀសមិនអោយមានកូដកម្មកើតឡើង ដោយសារតែបញ្ហានេះ។ រដ្ឋាភិបាលបានលើកឡើងថា ការសំរេចចិត្តផ្តល់ប្រាក់រង្វាន់ថ្មីនេះ គឺមានគោលបំណងដើម្បីដោះស្រាយបញ្ហាអតិផរណាដែលកើតឡើងថ្មីៗនេះ និងការកើនឡើងនូវតំលៃទំនិញជាបន្តបន្ទាប់។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងចេញជាសេចក្តីជូនដំណឹងក្នុងពេលឆាប់ៗនេះ ដែលនឹងបញ្ជាក់បន្ថែមពីរបៀបអនុវត្តប្រាក់បន្ថែមនេះ។



# អនុសញ្ញារួម ផ្តល់អត្ថប្រយោជន៍ដល់គ្រប់ភាគីទាំងអស់នៅក្នុងឧស្សាហកម្មកាត់ដេរ

*តមកពីទំព័រទី ១*

លោក ចន រីតឆតត៍ (John Ritchotte) ប្រធានទីប្រឹក្សាបច្ចេកទេសនៃគំរោងដោះស្រាយវិវាទការងារ (LDRP) របស់អង្គការពលកម្មអន្តរជាតិបានមានប្រសាសន៍ថា “គន្លឹះនៃការចរចារប្រកបដោយប្រសិទ្ធភាព គឺភាពជាតំណាងរបស់សហជីព។ អ្នកគ្រប់គ្រង ត្រូវតែដឹងថាពួកគេកំពុងតែចរចារជាមួយនឹងអ្នកណា ហើយអ្នកទាំងនោះតំណាងអោយអ្នកណាខ្លះ។ អ្នកពិតជាមិនចង់ចរចារជាមួយនឹងមនុស្សច្រើននាក់ ដែលមានការទាមទារផ្សេងៗពីគ្នានោះឡើយ”។

អនុសញ្ញារួម គឺជាកិច្ចព្រមព្រៀងស្ម័គ្រចិត្ត កើតឡើងដោយការចរចាររវាងសហជីព និងអ្នកគ្រប់គ្រងរោងចក្រ។ កិច្ចព្រមព្រៀងនេះចែងពីលក្ខខណ្ឌការងារ (ជាធម្មតាលើសពីអ្វីដែលចែងក្នុងច្បាប់) និងកាតព្វកិច្ចរបស់ភាគីទាំងសងខាង ហើយអាចអនុវត្តបានទៅតាមច្បាប់។ វាគឺជាកិច្ចសន្យាជាសមូហភាពមួយរវាងសហជីព និងសមាជិករបស់ខ្លួនជាមួយនឹងអ្នកគ្រប់គ្រង។ ដូចគ្នានឹងកិច្ចសន្យាល្អៗផ្សេងទៀតដែរ អនុសញ្ញារួមគួរមានចែងពីនីតិវិធីដោះស្រាយវិវាទ។ នៅក្នុងបណ្តាប្រទេសជាច្រើន នីតិវិធីដោះស្រាយវិវាទរួមមានសេចក្តីបង្គាប់ពីអាជ្ញាកណ្តាលដែលចងកាតព្វកិច្ចជាស្ថាពរ។ អង្គការពលកម្មអន្តរជាតិលើកកំពស់អោយមានការប្រើប្រាស់សេចក្តីបង្គាប់ពីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលចងកាតព្វកិច្ចជាស្ថាពរ ដែលជាមធ្យោបាយល្អបំផុតដើម្បីបង្ការវិវាទមិនអោយក្លាយជាកូដកម្ម ឬ ឡុកអៅ។ ការប្រើប្រាស់យន្តការបែបនេះមានន័យថា ភាគីមួយអាចជ្រើសយកកូដកម្ម ឬ ឡុកអៅជាជម្រើសចុងក្រោយលុះត្រាតែភាគីមួយទៀតមិនបានអនុវត្តទៅតាមសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែប៉ុណ្ណោះ។ ដូច្នេះ សេចក្តីបង្គាប់ពីអាជ្ញាកណ្តាលដែលចងកាតព្វកិច្ចជាស្ថាពរ ត្រូវនៅជាមួយគ្នានឹងខចែងអំពី “គ្មានកូដកម្ម គ្មានឡុកអៅ” មានន័យថា ភាគីទាំងអស់ត្រូវលះបង់សិទ្ធិធ្វើកូដកម្ម ឬ ឡុកអៅរបស់ខ្លួនក្នុងអាយុកាលកំណត់របស់អនុសញ្ញារួម។

ការបោះជំហានចេញពីការចរចារដើម្បីដោះស្រាយកូដកម្មដែលកើតឡើងភ្លាមៗ មកជាការចរចារអនុសញ្ញារួម ទាមទារអោយភាគីទាំងសងខាងផ្លាស់ប្តូរឥរិយាបថរបស់ខ្លួនយ៉ាងច្រើន។ សហជីពត្រូវការពេលវេលាមួយយ៉ាងវែងដើម្បីធ្វើការរៀបចំ និងពិគ្រោះយោបល់ជាមួយនឹងសមាជិករបស់ខ្លួន។ សហជីពត្រូវដាក់អាទិភាព និងប៉ាន់ប្រមាណតំលៃនៃការទាមទាររបស់ខ្លួន។ ពួកគេត្រូវតែដឹងថា តើអ្វីដែលពួកគេស្នើសុំពីនិយោជកត្រូវការការចំណាយប៉ុន្មានគិតជាដុល្លា។ លើសពីនេះទៅទៀត សហជីពត្រូវយល់ដឹងពីសមត្ថភាពរបស់និយោជកដើម្បីរ៉ាប់រងការចំណាយទាំងនេះ មានន័យថា សហជីពត្រូវមានការយល់ដឹងជាមូលដ្ឋានអំពីសេដ្ឋកិច្ចរបស់ឧស្សាហកម្មកាត់ដេរ។ ជាចុងក្រោយ បញ្ជីនៃការទាមទារត្រូវតែសមហេតុសមផល និងអាចសំរេចទៅបាន។

ជារឿយៗ អ្នកគ្រប់គ្រងតែងតែបដិសេធមិនព្រមចរចារជាមួយនឹងសហជីពដោយសារតែមូលហេតុជាច្រើនៈ ពួកគេខ្លាចសហជីពដទៃទៀតប្រឆាំង ឬ ខ្លាចសហជីពទាមទារអ្វីដែលមិនសមហេតុសមផល ឬ ពួកគេជឿថា កាតព្វកិច្ចតែមួយគត់របស់និយោជកគឺត្រូវធ្វើតាមច្បាប់ស្តីពីការងារ ហើយមិនត្រូវចរចារចំពោះលក្ខខណ្ឌទាំងឡាយណា ដែលលើសពីអ្វីដែលច្បាប់បានផ្តល់អោយនោះឡើយ។

ប៉ុន្តែ អនុសញ្ញារួមអាចជាឧបករណ៍មួយដ៏មានប្រយោជន៍សម្រាប់និយោជកផងដែរ។ អ្នកគ្រប់គ្រងអាច និងគួរតែទាមទារទៅលើសហជីពវិញ ឧទាហរណ៍ពាក់ព័ន្ធនឹងការកំណត់ពីបុព្វសិទ្ធិរបស់អ្នកគ្រប់គ្រងវិន័យក្នុងកន្លែងការងារ ផលិតភាព និងបញ្ហាផ្សេងទៀត ដែលខ្លួនគិតថាពាក់ព័ន្ធ។ បើតាមប្រកាសលេខ ៣០៥ អ្នកគ្រប់គ្រងត្រូវតែចរចារជាមួយនឹងសហជីពដែលមានភាពជាតំណាងបំផុត ប្រសិនបើសហជីពដែលមានភាពជាតំណាងបំផុតនេះ ស្នើសុំអោយមានការចរចារបែបនេះ។ ជាចុងក្រោយ សហជីពដែលមានភាពជាតំណាងបំផុតមានកាតព្វកិច្ចកំណត់ដោយច្បាប់ថាត្រូវតំណាងអោយកម្មករនិយោជិតទាំងអស់នៅក្នុងសហគ្រាស ហើយអង្គការពលកម្មអន្តរជាតិលើកទឹកចិត្តអោយសហជីពដែលមានភាពជាតំណាងបំផុត ធ្វើការពិគ្រោះយោបល់ជាមួយនឹងសហជីពភាគតិចនៅក្នុងការរៀបចំរបស់ខ្លួន។ សហជីពភាគតិចមិនមានសិទ្ធិធ្វើការទាមទារបក ឬ ស្នើសុំធ្វើអនុសញ្ញារួមដោយឡែកជាមួយនឹងនិយោជកឡើយ។

ចំនុចចុងក្រោយនេះអាចធ្វើអោយកាន់តែប្រសើរដោយខចែងបទដ្ឋានបន្ថែមចំនួនពីរ។ ខចែងអំពី “មិនមានការទាមទារបន្ថែម” មានន័យថា នៅពេលដែលកិច្ចព្រមព្រៀងត្រូវបានចុះហត្ថលេខារួចហើយ ពុំមានភាគីណាមួយអាចស្នើសុំសិទ្ធិ ឬ អត្ថប្រយោជន៍បន្ថែមក្នុងមួយអាយុកាលកំណត់របស់កិច្ចព្រមព្រៀងនេះឡើយ។ តាមពិតទៅ ការពិគ្រោះយោបល់ជាទៀងទាត់ នីតិវិធីដោះស្រាយការកើតទុក្ខមិនសុខចិត្ត និងកិច្ចសន្ទនាសង្គមក្នុងទម្រង់ផ្សេងទៀតគួរបន្តមានទៀត ប៉ុន្តែការចរចារជាផ្លូវការត្រូវតែបញ្ចប់ដោយដាច់ណាត់។ ខចែងអំពី “ភាគីបន្តបន្ទាប់” ចងកាតព្វកិច្ចសហជីពថ្មីៗ ដែលបង្កើតឡើងនៅក្នុងសហគ្រាសជាមួយនឹងកិច្ចព្រមព្រៀងដែលមានស្រាប់នេះ។

ការចរចារនានា អាចជាបញ្ហាចោទ នៅពេលដែលនិយោជកយល់ថាកម្មករនិយោជិតទាមទារច្រើនហួសហេតុពេក ឬ និយោជកមិនយល់អំពីដំណើរការនៃការបង្កើតអនុសញ្ញារួម។ ជាជំនួសអោយភាគីខាងនិយោជក និយោជិកប្រហែលបញ្ជូនបុគ្គលិកអោយមកកាន់តុចរចារ ដោយបុគ្គលិកទាំងនេះមិនមានសិទ្ធិធ្វើកិច្ចព្រមព្រៀងឡើយ។ ការប្រកួតប្រជែងគ្នារវាងសហជីព និងសហជីព និងការជឿទុកចិត្តគ្នាក្នុងកំរិតមួយទាប ជាទូទៅរវាងសហជីព និងសហជីព និងរវាងសហជីព និងអ្នកគ្រប់គ្រង បង្កើតអោយមានការពិបាកស្មុគស្មាញជាច្រើនបន្ថែមទៀត។ ចាំបាច់ត្រូវតែមានការខិតខំប្រឹងប្រែងពីគ្រប់ភាគីទាំងអស់។ លោក លី តេកហេង អ្នកគ្រប់គ្រងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) មានប្រសាសន៍ថា “អនុសញ្ញារួមមួយ អាចផ្តល់អត្ថប្រយោជន៍ទៅបាន តែនៅពេលដែលអនុសញ្ញារួមនោះ ត្រូវបានគេអនុលោមទៅតាមយ៉ាងពេញលេញប៉ុណ្ណោះ ហើយការចរចារនានាត្រូវធ្វើឡើងដោយសុច្ឆន្ទៈល្អ”។

អនុសញ្ញារួមដែលមានគុណភាពខ្ពស់ អាចកាត់បន្ថយវិវាទ បង្កើនផលិតភាព និងកែលំអលក្ខខណ្ឌការងារ។ រោងចក្រ និងសហជីព ដែលប្តេជ្ញាចិត្តមិនធ្វើកូដកម្មជាថ្នូរនឹងសេចក្តីបង្គាប់ពីអាជ្ញាកណ្តាលដែលចងកាតព្វកិច្ច អាចធានាចំពោះអ្នកបញ្ជាទិញថា ផលិតកម្មរបស់ពួកគេនឹងមិនរាំងស្ទះដោយសារតែវិវាទឡើយ។ ចំនុចនេះអាចជាកត្តាដ៏សំខាន់មួយ ដើម្បីទាក់ទាញការបញ្ជាទិញ ជាពិសេសនៅក្នុងប្រទេសកម្ពុជា។ ខណៈពេលដែលមានការយល់ដឹងកាន់តែច្រើនឡើងអំពីអត្ថប្រយោជន៍ជាសក្តានុពលទាំងនេះ ចំនួនអនុសញ្ញារួមដែលមានគុណភាពខ្ពស់នៅក្នុងឧស្សាហកម្មកាត់ដេរនៅមានចំនួនតិចនៅឡើយ។ ប៉ុន្តែ នៅទីណាដែលមានអនុសញ្ញារួម ទីនោះអនុសញ្ញារួមត្រូវបានទាំងអ្នកគ្រប់គ្រងទាំងសហជីពគោរព និងអនុវត្តតាម។ នេះបង្ហាញថា អនុសញ្ញារួមអាចមានប្រសិទ្ធភាពនៅទីនេះ។

គ្រប់ភាគីទាំងអស់ សុទ្ធតែមានការប្តេជ្ញាចិត្ត ដើម្បីសំរេចការងារនេះ។ សហជីព ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងថ្មីៗនេះ នាយករដ្ឋមន្ត្រី សុទ្ធតែបានសំដែងនូវការគាំទ្ររបស់ពួកគេចំពោះអនុសញ្ញារួម ដោយចាត់ទុកអនុសញ្ញារួមថាជាមធ្យោបាយមួយដើម្បីកាត់បន្ថយវិវាទ។ ប្រទេសកម្ពុជាក៏កំពុងស្ថិតនៅលើមាគ៌ាមួយសំដៅទៅរកស្ថានភាពបែបនេះផងដែរ។ បើតាមប្រសាសន៍របស់លោក លី តេកហេង ការធ្វើការរួមគ្នាលើកិច្ចការងារនេះ នឹងបង្ហាញថាឧស្សាហកម្មនេះមានបរិយាកាសការងារមួយយ៉ាងល្អ ហើយបង្ហាញផងដែរថា និយោជិត និងនិយោជក ចេះគោរពគ្នាទៅវិញទៅមក។ លោកមានប្រសាសន៍ថា “នេះគឺជាសក្ខីភាពគ្មានដែនកំណត់មួយបង្ហាញទៅកាន់ប្រទេស តំបន់ និងពិភពលោកថា ប្រទេសកម្ពុជា គឺជាទីកន្លែងសម្រាប់បោះទុនវិនិយោគ”។

ក្នុងពេលជាមួយគ្នានេះដែរ អ្នកបញ្ជាទិញអាចសួរទៅកាន់រោងចក្រថាតើពួកគេមានសហជីពដែលមានភាពជាតំណាងបំផុតដែរឬទេ ហើយអាចជំរុញរោងចក្រទាំងនោះ មិនអោយរារាំងដល់ការដាក់ពាក្យសុំភាពជាតំណាងបំផុតពិតប្រាកដ។ រោងចក្រក៏គួរមានការលើកទឹកចិត្តអោយចូលរួមនៅក្នុងការចរចារប្រកបដោយសុច្ឆន្ទៈផងដែរ បើទោះបីជាកិច្ចព្រមព្រៀងគឺអាស្រ័យទៅតាមភាគីខ្លួនឯងក៏ដោយ។ “អនុសញ្ញារួមដែលល្អ គឺជាជោគជ័យមួយ ព្រោះគ្រប់គ្នាសុទ្ធតែបានចូលរួម និងមានភាពពាក់ព័ន្ធ” នេះបើតាមប្រសាសន៍របស់លោក ចន រីតឆតត៍ (John Ritchotte)។

# អ្នកផ្តល់សេវាបណ្តុះបណ្តាល ធ្វើការងារដើម្បីបង្កើនផលិតភាព និងកែលំអទំនាក់ទំនងនៅកន្លែងធ្វើការ

កាលពីខែ វិច្ឆិកា ឆ្នាំទៅ គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* (BFC) នៃអង្គការពលកម្មអន្តរជាតិ បានរៀបចំសិក្ខាសាលាមួយ សម្រាប់អ្នកផ្តល់សេវាបណ្តុះបណ្តាលដល់ឧស្សាហកម្មកាត់ដេរកម្ពុជា។ កិច្ចប្រជុំនេះមានគោលបំណងនាំគ្រប់អ្នកដែលមានការពាក់ព័ន្ធទាំងអស់អោយមកជួបជុំគ្នា ដើម្បីរៀបចំបង្កើតផែនការបណ្តុះបណ្តាលសម្រាប់បណ្តាឆ្នាំខាងមុខ។ កិច្ចប្រជុំនេះក៏មានគោលបំណងបង្កើនការយល់ដឹង ពីគំនិតផ្តួចផ្តើមខាងការបណ្តុះបណ្តាលនានាជាច្រើន និងកំណត់ពីឱកាសដើម្បីធ្វើការសហការគ្នា។ ការបង្កើតស្ថាប័នផ្សព្វផ្សាយព័ត៌មានស្តីពីសេវាបណ្តុះបណ្តាល ក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ ដើម្បីយកមកធ្វើជាគំរូមួយ សំដៅធ្វើអោយការចែករំលែកព័ត៌មាន និងការសហការគ្នាកាន់តែមានភាពល្អប្រសើរ។ កិច្ចប្រជុំនេះបានផ្តល់លទ្ធផលជាវិជ្ជមាន ហើយគ្រប់ភាគីទាំងអស់បានព្រមព្រៀងគ្នាថា ការប្រាស្រ័យទាក់ទង និងការសហការគ្នាដែលល្អប្រសើរនឹងអាចបំពេញទៅតាមសេចក្តីត្រូវការរបស់ឧស្សាហកម្មនេះបានកាន់តែល្អផងដែរ។


កិច្ចប្រជុំប្រឹក្សាកែលំអរោងចក្ររវាងសហជីព និងអ្នកគ្រប់គ្រង

ការបណ្តុះបណ្តាលត្រូវបានទទួលស្គាល់តាំងពីយូរណាស់មកហើយថាជាយុទ្ធសាស្ត្រគន្លឹះមួយរបស់អ្នកផ្តល់ជំនួយធំៗ ដែលបានធ្វើការងារកសាងសមត្ថភាព និងជំនាញដើម្បីធានាថា ប្រជាជនកម្ពុជាអាចពង្រឹងស្ថាប័ន និងការអនុវត្តន៍របស់ខ្លួន និងធ្វើការងារប្រកបដោយសមត្ថភាព និងប្រសិទ្ធភាព។

ឧស្សាហកម្មកាត់ដេរ មានសារៈសំខាន់យ៉ាងខ្លាំងចំពោះការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចរយៈពេលវែងរបស់ប្រទេសកម្ពុជា។ លោក ខនន័រ ប៊ិយ (Conor Boyle) ប្រធានផ្នែកបណ្តុះបណ្តាល នៃគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* (BFC) កត់សំគាល់ថា ដើម្បីរក្សានូវជោគជ័យ និងបង្កើនផលិតភាពរបស់ខ្លួន «ជាការសំខាន់ណាស់ ដែលត្រូវផ្តល់ជាជម្រើសបណ្តុះបណ្តាល និងការកសាងសមត្ថភាព ទៅអោយអ្នកដែលមានការពាក់ព័ន្ធនៅក្នុងឧស្សាហកម្ម»។

ជាទូទៅ ការបណ្តុះបណ្តាលផ្តល់ជាដំណោះស្រាយរយៈពេលវែង ដើម្បីអោយរោងចក្របង្កើនសមត្ថភាពរបស់ខ្លួន។ បន្ទាប់ពីបុគ្គលិកម្នាក់ ឬ អ្នកគ្រប់គ្រងម្នាក់ទទួលបានការបណ្តុះបណ្តាលរួចមក ចំណេះដឹងដែលពួកគេទទួលបានអាចផ្ទេរបន្ត ចែករំលែក និងប្រើប្រាស់ជាផ្នែកនៃយុទ្ធសាស្ត្រទូលំទូលាយមួយសំដៅបង្កើតនូវបរិយាកាសការងារមួយដែលមានប្រសិទ្ធភាព។

សម្រាប់**គំរោងអប់រំចលនាសហជីព (WEP)** របស់អង្គការពលកម្មអន្តរជាតិ កិច្ចខិតខំប្រឹងប្រែងរយៈពេលវែងនេះរួមមាន ការកសាងសមត្ថភាពសម្រាប់អ្នកដែលចូលរួមជាមួយនឹងសហជីព ដែលមានសកម្មភាពនៅក្នុងឧស្សាហកម្មកាត់ដេរ។ លោក នួន វាសនា អ្នកគ្រប់គ្រងគំរោងថ្នាក់ជាតិនៃគំរោងអប់រំចលនាសហជីព បានមានប្រសាសន៍បញ្ជាក់ថា៖ «ការបណ្តុះបណ្តាលគឺជាដំណោះស្រាយរយៈពេលវែង... អ្នកនឹងមានទំនាក់ទំនងវិជ្ជាជីវៈប្រសើរជាងមុន នៅពេលដែលអ្នកនៅក្នុងឧស្សាហកម្មកាន់តែមានការយល់ដឹងពីសិទ្ធិ តួនាទី និងការទទួលខុសត្រូវរបស់ខ្លួន»។

ស្ថាប័នមួយទៀតដែលធ្វើការងារខាងទំនាក់ទំនងវិជ្ជាជីវៈដែរនោះគឺ **មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)** (www.clec.org.kh)។ អង្គភាពកម្មវិធីការងារ (LPU) របស់មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ បានបង្កើត និងរៀបចំអោយមានជាកម្មវិធីបណ្តុះបណ្តាលស្តីពីទំនាក់ទំនងវិជ្ជាជីវៈ និងការដោះស្រាយវិវាទការងារ ដែលមានការចូលរួមពីសិក្ខាកាមដែលមានការពាក់ព័ន្ធជាច្រើន ដូចជានិយោជក និយោជិត និងតំណាងមកពីសហជីព ស្ថាប័នតុលាការ និងរដ្ឋាភិបាល។ បន្ថែមពីលើនេះទៅទៀត CLEC ក៏បានធ្វើការបោះពុម្ពផ្សាយឯកសារដែលមានពាក់ព័ន្ធផងដែរ។

បន្ថែមពីលើការកែលំអទំនាក់ទំនងវិជ្ជាជីវៈ ការបណ្តុះបណ្តាល បានរួមចំណែកក្នុងការបង្កើនផលិតភាព និងសមត្ថភាពប្រកួតប្រជែង។ លោកស្រី ជេនី ភៀសុន (Jenny Pearson) នាយិកា **វិទ្យាស្ថានបំរើអ្នកសំរបសំរួលការងារអភិវឌ្ឍន៍ (VBNK)** (www.vbnk.org) ដែលជាអង្គការក្រៅរដ្ឋាភិបាលមានឯកទេសខាងកសាងសមត្ថភាព បានមានប្រសាសន៍ថា ការបណ្តុះបណ្តាលគឺជាកូនសោរ ដើម្បីជួយអោយឧស្សាហកម្មកាត់ដេរទទួលបាននូវ «ចំណេះដឹង ជំនាញ និងបទពិសោធន៍ ដែលខ្លួនត្រូវការដើម្បីរក្សាអោយបាននូវភាពរីកចំរើនរបស់ខ្លួន និងនៅតែឈរជួរមុខគេក្នុងការប្រកួតប្រជែងជាសកល»។ VBNK មានឈ្មោះបោះសំលេង ដោយសារតែវិទ្យាស្ថាននេះប្រើប្រាស់នូវវិធីសាស្ត្រដែលមានការចូលរួមបែបអនុវត្តដោយផ្ទាល់ ដើម្បីជំនះឧបសគ្គនានានៃការសិក្សា និងការផ្លាស់ប្តូរ។ ក្នុងនាមជាដៃគូរបស់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* តាំងពីឆ្នាំ ២០០៥ មក **VBNK** ផ្តល់ជាកម្មវិធីបណ្តុះបណ្តាលតាមម៉ូឌុលរបស់គំរោងនេះ ទៅអោយអ្នកគ្រប់គ្រង និងសហជីព ឬ តំណាងកម្មករនិយោជិតរបស់រោងចក្រកាត់ដេរនានា។ **VBNK** ក៏ផ្តោតផងដែរទៅលើសារៈសំខាន់នៃការកសាងសមត្ថភាពអោយស្ត្រីក្មេងៗ ដែលជាក្រុមគ្មានតំណាងជាយូរមកហើយ ប៉ុន្តែជាក្រុមដែលមានសារៈសំខាន់យ៉ាងធំធេងនៅក្នុងវិស័យកាត់ដេរ។

ដោយមានគោលបំណងរក្សាអោយបាននូវសមត្ថភាពប្រកួតប្រជែងជាសកលរបស់កម្ពុជាផងដែរនោះ **សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)** (www.gmac-cambodia.org) ដែលតំណាងអោយរោងចក្រផលិតសម្រាប់ការនាំចេញ មានគោលបំណងអភិវឌ្ឍន៍សមត្ថភាពរបស់បុគ្គលិក និងអ្នកគ្រប់គ្រងរោងចក្រ ដែលជារឿយៗ ធ្វើឡើងតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញកាត់ដេរកម្ពុជា (CGTC)។ GMAC ផ្តល់ការបណ្តុះបណ្តាលលើគ្រប់ផ្នែកទាំងអស់នៃឧស្សាហកម្មម៉ូដសំលៀកបំពាក់ រាប់ពីការរចនាម៉ូដ រហូតដល់ការបញ្ជូនទំនិញចេញ។ **មជ្ឈមណ្ឌលឧស្សាហកម្មដើម្បីបង្កើនលទ្ធភាពផលិតសំលៀកបំពាក់ (GIPC)** (www.gipc.org.kh) ផ្តល់ការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំរបស់រោងចក្រ ស្តីពីការគ្រប់គ្រងផ្នែកផលិតកម្ម និងបណ្តុះបណ្តាលគ្រូបង្គោល ក្នុងគោលបំណងដើម្បីធានាអោយមាននិរន្តរភាពនាពេលអនាគត។

ដោយធ្វើការគ្របដណ្តប់លើសមត្ថភាពប្រកួតប្រជែងផង និងលើទំនាក់ទំនងវិជ្ជាជីវៈផង **គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* (BFC)** (www.betterfactories.org/ilo) បានផ្តោតទៅលើលក្ខខណ្ឌការងារ ផលិតភាព និងគុណភាព តាមរយៈកិច្ចសហការនៅកន្លែងការងារ។ ដូចគ្នានឹងកម្មវិធីបណ្តុះបណ្តាលតាមម៉ូឌុលជាមួយនឹង VBNK ដែរ BFC ផ្តល់នូវសិក្ខាសាលាបណ្តុះបណ្តាល ការបណ្តុះបណ្តាលកញ្ចប់ណែនាំការងារ ការបណ្តុះបណ្តាលតាមរោងចក្រសម្រាប់កម្មករ និយោជិត និងការបណ្តុះបណ្តាលជំនាញសម្រាប់មេការ និងអ្នកគ្រប់គ្រងជាន់ខ្ពស់។ BFC ក៏ទើបតែបង្កើតអោយមានជាសេវាពិគ្រោះយោបល់ផងដែរ ដែលសេវាទាំងនេះបំពេញទៅតាមសេចក្តីត្រូវការជាក់ស្តែងរបស់សហគ្រាសនីមួយៗ។ សិក្ខាកាមដែលជាគោលដៅរួមមានទាំងអ្នកគ្រប់គ្រង ទាំងតំណាងសហជីព៖ BFC ជឿជាក់លើការរៀនជាមួយគ្នាដើម្បីយល់ដឹងពីគ្នាទៅវិញទៅមក។ វិធីសាស្ត្របណ្តុះបណ្តាល ជាវិធីសាស្ត្រដែលមានការចូលរួម ហើយ BFC បានធ្វើការតាមដានលើសិក្ខាកាម បើទោះបីជាការទទួលខុសត្រូវចុងក្រោយ សម្រាប់ការកែលំអរោងចក្រ គឺស្ថិតលើសិក្ខាកាម និងអ្នកមកពីរោងចក្រក៏ដោយ។

ការបណ្តុះបណ្តាល មិនមែនចេះតែរលូនទៅមុខនោះទេ ព្រោះអ្នកផ្តល់សេវាបណ្តុះបណ្តាលបានពេបប្រទះជាមួយនឹងបញ្ហាប្រឈមជាច្រើនផងដែរ។ ជាក់ស្តែង ការដាក់អ្នកគ្រប់គ្រង និងតំណាងកម្មករនិយោជិតអោយរៀនជាមួយគ្នា អាចជាការមួយពិបាក ដោយសារតែមូលហេតុជាច្រើន។ ជាពិសេសតំណាងកម្មករនិយោជិតពុំមានបទពិសោធន៍ ជាមួយនឹងការបណ្តុះបណ្តាលដែលមានការចូលរួមឡើយ ហើយពួកគេមិនធ្លាប់ត្រូវបានគេស្នើអោយបញ្ចេញគំនិតយោបល់ឡើយ។ ដូចគ្នានឹងប្រសាសន៍របស់លោក នួន វាសនា «យើងចាំបាច់ត្រូវតែផ្តល់ការបណ្តុះបណ្តាលបន្ថែមទៀតដល់កម្មករនិយោជិត ហើយត្រូវកែសំរួលកម្មវិធី និងឯកសារបណ្តុះបណ្តាលនានា អោយសមស្របជាមួយនឹងពួកគេអោយបានកាន់តែប្រសើរជាងមុន»។

តែទោះជាយ៉ាងណាក៏ដោយ ឥលូវនេះ កម្មវិធីបណ្តុះបណ្តាលទូលំទូលាយមួយ គឺមានរួចជាស្រេច។ បញ្ហាគន្លឹះមួយ ដែលត្រូវយកមកបន្តពិចារណាគឺជាការចូលរួមពីអ្នកដែលមានការពាក់ព័ន្ធក្នុងប្រទេស ទៅលើការផ្តល់ការបណ្តុះបណ្តាល។ លោក ប៊ិយ (Boyle) មានប្រសាសន៍ថា «ជាការសំខាន់នាពេលអនាគត យើងគួរតែចូលរួមជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្តល់នូវសេវាបណ្តុះបណ្តាលទៅអោយឧស្សាហកម្មកាត់ដេរ»។

ចាំបាច់ក៏ត្រូវមានការផ្តោតបន្ថែមលើការអភិវឌ្ឍន៍គ្រូបង្គោល និងស្ថាប័នបណ្តុះបណ្តាលក្នុងស្រុកផងដែរ។ បើតាមគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ប្រសិនបើឧស្សាហកម្មកាត់ដេរកម្ពុជាចង់មាននិរន្តរភាពរយៈពេលវែងសំខាន់បំផុត គឺត្រូវបង្កើតអោយមានអ្នកជំនាញខាងបណ្តុះបណ្តាលក្នុងស្រុកមួយក្រុមធំ។

លើសពីនេះទៅទៀត ជាការសំខាន់ដែលអ្នកផ្តល់សេវាបណ្តុះបណ្តាលធ្វើការសហការគ្នា ដើម្បីធានាអោយបានច្បាស់ថា ម្នាក់ៗធ្វើការងារក្នុងផ្នែកដែលជាឯកទេសផ្ទាល់ខ្លួនរបស់ពួកគេ។ លោក ប៊ិយ (Boyle) គិតថាអ្នកផ្តល់សេវាបណ្តុះបណ្តាលចាំបាច់ត្រូវធ្វើការរួមគ្នា ដើម្បីកាត់បន្ថយភាពជាន់គ្នា និងដើម្បីធានាថា គ្រប់តម្រូវការខាងការបណ្តុះបណ្តាលទាំងអស់ សុទ្ធតែបានបំពេញ។ «ស្ថាប័ននីមួយៗ គួរកំណត់ពីជំនាញបណ្តុះបណ្តាលរបស់ខ្លួន ហើយផ្តល់សេវាកម្មដែលខ្លួនមានឯកទេស។ តាមរយៈការធ្វើការងាររួមគ្នា យើងអាចបំពេញនូវសេចក្តីត្រូវការរបស់ឧស្សាហកម្ម ដែលមានសារៈសំខាន់បំផុតរបស់ប្រទេសកម្ពុជាបាន»។

ព័ត៌មានបន្ថែមស្តីពីគ្រប់អ្នកផ្តល់សេវាទាំងនេះ មាននៅលើទំព័របណ្តុះបណ្តាលរបស់វិបសាយនៃគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ឬ វិបសាយផ្ទាល់របស់ស្ថាប័ននីមួយៗ»។

# ស្នាដៃដែលទទួលបានជោគជ័យនៅក្នុងការប្រកួតប្រជែង "ខ្ញុំមានតំលៃ" នឹងចូលរួមនៅក្នុងពិព័រណ៍ទេសចរណ៍

*តមកពីទំព័រទី ១*

យុទ្ធនាការ និងការប្រកួតប្រជែងនេះ ត្រូវបានសហការរៀបចំដោយគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) នៃអង្គការពលកម្មអន្តរជាតិ ក្រសួងកិច្ចការនារី (MoWA) សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) មជ្ឈមណ្ឌលឧស្សាហកម្មដើម្បីបង្កើនលទ្ធភាពផលិតសំលៀកបំពាក់ (GIPC) មូលនិធិអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិសម្រាប់ស្ត្រី (UNIFEM) សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងទស្សនាវដ្តីតំលៃនារី។


សែម សុខនី បង្ហាញម៉ូដរ៉ូបឈ្នះជ័យលាភី ដែលនាងបានច្នៃ

កិច្ចសហការដ៏វិជ្ជមានរវាងអ្នកផ្តល់ជំនួយធំៗ និងអ្នកដែលមានការពាក់ព័ន្ធនេះ នឹងបន្តមានទៀតនៅក្នុងពេលអនាគតដ៏ខ្លីខាងមុខ។ ឥលូវនេះ គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* កំពុងប្រើប្រាស់សំលៀកបំពាក់ និងបទចំរៀងរបស់អ្នកដែលជាប់នៅក្នុងវគ្គផ្តាច់ព្រ័ត្រទាំងអស់ ដើម្បីបង្កើតជាពិពណ៌ទេសចរណ៍មួយដែលនឹងរួមមាន ខ្សែវីដេអូ និងរឿងរ៉ាវនានា អំពីការប្រកួតប្រជែងនេះ។ ពិពណ៌នេះ នឹងអាចជួយអោយបុគ្គលិករបស់ក្រុមហ៊ុនអន្តរជាតិដែលបញ្ជាទិញសំលៀកបំពាក់ពីប្រទេសកម្ពុជា និងដែលកំពុងចូលរួមជាមួយនឹងគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដឹងពីជីវិតរបស់មនុស្សម្នាក់ៗ ដែលនៅពីក្រោយផលិតផល។ ក្នុងពេលជាមួយគ្នានេះ ក៏មានការផ្សារភ្ជាប់ទំនាក់ទំនងរវាងអ្នកដែលបញ្ជាទិញ និងអ្នកដែលផលិតសំលៀកបំពាក់ នៅតាមរោងចក្រកាត់ដេររបស់ប្រទេសកម្ពុជាផងដែរ។

**បទចំរៀងដែលទទួលបានជ័យជំនះ៖ «ខ្ញុំមានតំលៃ» ដោយកញ្ញា តូច ស្រីនិត**

*សំលេងរថយន្តលាចាកស្រុកទៅ បើកបរសំដៅទៅក្រុងភ្នំពេញ*
*ខ្ញុំលាពុកម៉ែទាំងចិត្តទោម្នេញ សង្ឃឹមវិលវិញមានប្រាក់ជូនម្តាយ*

*មកដល់ដីក្រុងក្នុងរោងចក្រមួយ ដែលជាជំនួយពីប្រទេសគេ*
*ការងាររោងចក្រកម្មករកាត់ដេរ បានប្រាក់ហូរហែរផ្ញើជូនទៅម្តាយ*

*ឱរោងចក្រអើយមានតែអ្នកហើយ អោយខ្ញុំបានស្បើយរួចពីទុក្ខា*
*ជីវិតរុងរឿងអនាគតថ្លៃថ្លា សង្គមគ្រួសារលែងជួបទុក្ខសោក*

*ម៉ែអើយនៅផ្ទះសូមម៉ែកុំព្រួយ ជីវិតកូនមួយមានតំលៃណាស់*
*ការងាររោងចក្រមិនមានអៀនខ្មាស ផ្តល់ផលច្រើនណាស់នៅក្នុងសង្គម*

# គំរោងរោងចក្រកាន់តែប្រសើរទទួលបានថវិកា

## ជិត ១,៥ លានដុល្លា ពីទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍របស់ប្រទេសបារាំង (AFD)

កាលពីពាក់កណ្តាលខែ មិនា ឆ្នាំ ២០០៨ នេះ ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍របស់ប្រទេសបារាំង (AFD) បានព្រម ព្រៀងផ្តល់មូលនិធិចំនួន ១ ៤៥៩ ២៩៣ ដុល្លាសហរដ្ឋអាមេរិក ដើម្បីធ្វើការកែលំអលក្ខខណ្ឌនៅក្នុងឧស្សាហកម្មកាត់ដេរ តាមរយៈគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* (BFC) នៃអង្គការពលកម្មអន្តរជាតិ។ ឧស្សាហកម្មកាត់ដេរគឺជាអ្នកទទួលថវិកាមួយក្នុងចំណោមអ្នកទទួលថវិកាចំនួនបី ដែលសរុបទទួលបានមូលនិធិចំនួន ១៤,៥ លានដុល្លាសហរដ្ឋអាមេរិក។ យោងតាមសំដីរបស់លោក អេរិក បិកនត (Eric Beugnot) នាយក AFD ប្រចាំប្រទេសកម្ពុជា ដែលបានដកស្រង់ចេញពីកាសែត The Mekong Times កាលពីថ្ងៃពុធ ទី ១២ មិនា ២០០៨ បានមានប្រសាសន៍ថា ប្រទេសកម្ពុជានឹងត្រូវប្រឈមនឹងការប្រកួតប្រជែងដ៏ស្វិតស្វាញ នៅពេលដែលការដាក់របាំងការពារលើប្រទេសចិនត្រូវដកចេញនៅចុងឆ្នាំ ២០០៨ នេះ។ ហេតុដូច្នេះហើយជំនួយដែលផ្តល់ដល់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* «នឹងជួយដល់ការពង្រឹងការគោរពច្បាប់ស្តីពីការងារ ការកែលំអលក្ខខណ្ឌការងារ សម្រាប់កម្មករនិយោជិត និងពង្រឹងសមត្ថភាពប្រកួតប្រជែង»។ បន្ទាប់ពីការចុះហត្ថលេខាលើមូលនិធិ ដែលត្រូវផ្តល់ទៅអោយគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*នេះរួចមក ឯកឧត្តម ហ្សង់_ហ្វ្រង់ស្វ័រ ដេស្មាស៊ីយែរ (Jean-François Desmazières) ឯកអគ្គរដ្ឋទូតរបស់ប្រទេសបារាំង ប្រចាំនៅកម្ពុជា បានមានប្រសាសន៍បញ្ជាក់ពីសារៈសំខាន់នៃការផ្តល់ជំនួយរបស់ AFD នេះថា អតិថិជនអ្នកប្រើប្រាស់នៅសហភាពអឺរ៉ុប កំពុងចង់ដឹងចង់លឺពីលក្ខខណ្ឌនៃការផលិតទំនិញដែលពួកគេប្រើប្រាស់។ ឯកឧត្តមបានបន្តទៀតថា គំរោងនានា ដូចជាគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*នេះជាដើម បានជួយបង្កើតអោយមានការយល់ដឹងពីលក្ខខណ្ឌការងារសមរម្យ ដែលជាទិដ្ឋភាពដ៏សំខាន់មួយនៃការធ្វើពាណិជ្ជកម្ម។

# ការតែងតាំងថ្មី



កាលពី ពេលថ្មីៗនេះគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានតែងតាំងកញ្ញា ហាស មីនា លីរ៉ាណា អោយបំពេញតួនាទីជាជំនួយការផ្នែកព័ត៌មានវិទ្យា (IT) ថ្មីរបស់ខ្លួន។ រ៉ាណាបានពាំនាំយកមកនូវបទពិសោធន៍ ពីវិស័យអង្គការក្រៅរដ្ឋាភិបាលមកអោយក្រុមការងារនៃគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*។ នាងទទួលខុសត្រូវលើគ្រប់តម្រូវការផ្នែក IT ទាំងអស់របស់គំរោង និងជាពិសេសដឹកនាំគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងព័ត៌មានបង្កើតថ្មីរបស់គំរោងទៀតផង។

# ឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី

## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិភាក្សាពីការផ្តល់មូលនិធិរបស់រដ្ឋាភិបាលជាមួយនឹង*រោងចក្រកាន់តែប្រសើរ* នាងវេទិការវាងរដ្ឋាភិបាល និងវិស័យឯកជនលើកទី ១៣

នៅក្នុងវេទិការវាងរដ្ឋាភិបាល និងវិស័យឯកជនលើកទី ១៣ ដែលត្រូវបានធ្វើឡើងនៅឯក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កាលពីថ្ងៃទី ២៣ មេសា ២០០៨ ឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានលើកឡើងអំពីការងារសំខាន់ៗរបស់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ក្នុងការធ្វើអោយលក្ខខណ្ឌការងារប្រសើរឡើង និងបានពិភាក្សាអំពីគំរោងនេះជាមួយលោក រ៉ូប៊ឺត ហ្សូលីក (Robert Zoellick) ប្រធានធនាគារពិភពលោក ក្នុងខណៈពេលដែលលោកមកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជា។

នៅក្នុងសុន្ទរកថារបស់ឯកឧត្តម គាត ឈន់ គាត់បានមានប្រសាសន៍ប្រាប់ដល់អ្នកចូលរួមថា រដ្ឋាភិបាលនឹងបន្តផ្តល់មូលនិធិទៅអោយគំរោងនេះ សម្រាប់កំឡុងពេលពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១១ ដើម្បីធានាថាគំរោងនេះនៅតែអាចបន្តផ្តល់សេវារបស់ខ្លួន ទៅអោយឧស្សាហកម្ម និងដើម្បីជួយដល់ដំណើរការអន្តរកាលរបស់គំរោងនេះ អោយក្លាយទៅជាស្ថាប័នក្នុងស្រុកមួយរបស់ប្រទេសកម្ពុជា។

វេទិការវាងរដ្ឋាភិបាល និងវិស័យឯកជននេះ គឺជាវេទិកាធ្វើឡើងពីរដងក្នុងមួយឆ្នាំដោយផ្សព្វផ្សាយទូទាំងប្រទេសដែលរដ្ឋមន្ត្រី និងតំណាងមកពីវិស័យឯកជននានាមកធ្វើការជួបប្រជុំគ្នា។ អ្នកដែលមានការពាក់ព័ន្ធ មានគោលដៅរួមគ្នា គឺដើម្បីកែលំអបរិយាកាសធុរកិច្ច និងបង្កើនវិនិយោគទុនឯកជន។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) របស់ធនាគារពិភពលោក ដើរតួជាលេខាធិការដ្ឋានសម្រាប់វេទិកានេះ។

# ធនធានថ្មីៗ

### មជ្ឈមណ្ឌលធនធាន

នាពេលថ្មីៗនេះ គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ បានបើកនូវមជ្ឈមណ្ឌលធនធានមួយ ដែលមានឯកសារជាច្រើនស្តីពីបញ្ហាដែលទាក់ទងនឹងឧស្សាហកម្មកាត់ដេរ។ មជ្ឈមណ្ឌលនេះ បើកចំពោះសិស្ស_និស្សិត និងមហាជនទូទៅ ដែលចាប់អារម្មណ៍លើឧស្សាហកម្មកាត់ដេរ និងការងាររបស់អង្គការពលកម្មអន្តរជាតិ។ មជ្ឈមណ្ឌលនេះបើកនៅរៀងរាល់ថ្ងៃច័ន្ទ ពីម៉ោង ៧.៣០_១២.០០ ព្រឹក និងថ្ងៃពុធ ពីម៉ោង ៧.៣០_១២.០០ ព្រឹក និងពីម៉ោង ១.៣០_៥.០០ សៀល។

### ខិតប័ណ្ណព័ត៌មាន

ខិតប័ណ្ណព័ត៌មានថ្មីមួយរបស់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ក្រោមប្រធានបទ«ឧស្សាហកម្មកាត់ដេរកម្ពុជាៈ បញ្ហាប្រឈម និងឱកាស» បានចេញផ្សាយកាលពីពេលថ្មីៗនេះ (ខែ មេសា ២០០៨) ដោយមានការវិភាគអំពីវិស័យកាត់ដេរនៅកម្ពុជាកំពុងតែលៃលកត្រៀមខ្លួន ក្នុងការប្រឈមនឹងសំពាធកើនឡើងជាសកល។

នៅក្នុងខិតប័ណ្ណព័ត៌មាននេះ គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* មានបង្ហាញអំពីទិន្នន័យសំខាន់ៗរបស់ក្រសួងពាណិជ្ជកម្ម និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងតួលេខដែលបានមកពីប្រព័ន្ធគ្រប់គ្រងព័ត៌មាន (IMS)។ បញ្ហាសំខាន់ៗដែលពាក់ព័ន្ធទៅនឹងការនាំចេញ ការងារ ប្រាក់ឈ្នួល និងទំនាក់ទំនងវិជ្ជាជីវៈក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ។

ខិតប័ណ្ណព័ត៌មាននេះមាននៅលើគេហទំព័ររបស់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ជាភាសាខ្មែរ អង់គ្លេស និងចិន www.betterfactories.org/ilo ក្រោមចំណងជើង «អំពីឧស្សាកម្ម»។



International Labour Organization

better factories Cambodia

**ឧស្សាហកម្មកាត់ដេរកម្ពុជាៈ បញ្ហាប្រឈម និង ឱកាស**

ក្នុងខែ ធ្នូ ឆ្នាំ 2008 ខាងមុខនេះ ការដាក់របាំងការពាររបស់សហរដ្ឋអាមេរិក ទៅលើការនាំចូលពីប្រទេសចិននឹងដល់ទីបញ្ចប់ ។ កូតារបស់អឺរ៉ុបក៏នឹងត្រូវបានដកចេញផងដែរ ហើយសហរដ្ឋអាមេរិកក៏កំពុងជួបប្រទះនឹងបញ្ហាសេដ្ឋកិច្ច - កត្តាទាំងអស់នេះ សុទ្ធតែជាកត្តាប៉ះពាល់ដល់ឧស្សាហកម្មកាត់ដេរកម្ពុជា ។ ខិតប័ណ្ណនេះនឹងបង្ហាញថា តើឧស្សាហកម្មកាត់ដេរសំរាប់ការនាំចេញរបស់ប្រទេសកម្ពុជា នឹងគ្រប់គ្រងកំណើនសំពាធនេះដោយរបៀបណា ។

**រូបភាពទី 1:** ការប្រៀបធៀបតំលៃនៃការនាំចេញសរុប 2001-2007 (គិតជាលាន US$)



(ប្រភពៈ ក្រសួងពាណិជ្ជកម្ម 2007)

**តើការនាំចេញនៅតែបន្តកើនឡើងដែរឬទេ ?**

បើទោះបីជាកំណើនមានភាពយឺតយ៉ាវក៏ដោយ ក៏តំលៃនៃការនាំចេញ បាននឹងកំពុងបន្តកើនឡើងជាបន្តទៀត ។ នៅក្នុងឆ្នាំ 2007 តំលៃសរុបនៃការនាំចេញសំលៀកបំពាក់របស់កម្ពុជា បានកើនឡើងដល់ជិត 2,8 ពាន់លានដុល្លារសហរដ្ឋអាមេរិក ។ នៅក្នុងឆ្នាំ 2006 តំលៃនៃការនាំចេញគឺ 2,6 ពាន់លានដុល្លារសហរដ្ឋអាមេរិក ដែលខ្ពស់ជាងឆ្នាំ 2005 ចំនួន 21% [1] ។ បើយោងតាមស្ថិតិស្តីពីការនាំចូលសំលៀកបំពាក់របស់សហរដ្ឋអាមេរិក ការនាំចូលពីប្រទេសកម្ពុជា បានកើនឡើងចំនួន 13.5% នៅក្នុងឆ្នាំ 2007 ។[2]

នៅក្នុងឆ្នាំ 2007 សហរដ្ឋអាមេរិកនៅតែជាទីផ្សារសំខាន់ជាងគេ សំរាប់ការនាំចេញសំលៀកបំពាក់ពីប្រទេសកម្ពុជា ។ ការនាំចេញទៅកាន់សហរដ្ឋអាមេរិកមានជាង 70% ហើយទៅកាន់អឺរ៉ុបមាន 22% ។[3] គំរូនៃការនាំចេញបែបនេះ បានបន្តមានជាច្រើនឆ្នាំ ។ ប្រទេសកម្ពុជា ពឹងផ្អែកទាំងស្រុងទៅលើទីផ្សាររបស់សហរដ្ឋអាមេរិក ដូច្នេះការថយចុះការបញ្ជាទិញពីក្រុមហ៊ុនលក់រាយរបស់អាមេរិចពិតជាមានផលប៉ះពាល់ដល់ការនាំចេញ ។

**តើវាមានន័យយ៉ាងណាចំពោះការងារ ?**

នៅរវាងថ្ងៃទី 1 មករា 2006 ដល់ 31 ធ្នូ 2007 ការងារថ្មីចំនួនជាង 62 000 ត្រូវបានបង្កើតឡើងនៅក្នុង

[1] ក្រសួងពាណិជ្ជកម្ម 2007
[2] របាយការណ៍ស្ថិតិស្តីពីការនាំចូលសំលៀកបំពាក់របស់សហរដ្ឋអាមេរិក នៅក្នុងឆ្នាំ 2004-2007
[3] ក្រសួងពាណិជ្ជកម្ម 2007
[4] ibid
[5] ibid


ព្រឹត្តិប័ត្រនេះ ត្រូវបានបោះពុម្ពផ្សាយដោយគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ ។
ទស្សនៈទាំងឡាយនៅក្នុងព្រឹត្តិប័ត្រនេះ មិនជាចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈជាផ្លូវការរបស់អង្គការពលកម្មអន្តរជាតិឡើយ ។



ផ្ទះលេខ ៩ ផ្លូវលេខ ៣២២ សង្កាត់បឹងកេងកងទី ១ ភ្នំពេញ កម្ពុជា _ ប្រអប់សំបុត្រលេខ ២៦៤២
ទូរស័ព្ទ : (៨៥៥_២៣) ២១២ ៨៤៧ លេខបន្ត ១០៦ _ ទូរសារ : (៨៥៥_២៣) ២១២ ៩០៣
សម្រាប់ការទទួលយកព្រឹត្តិប័ត្រអេឡិចត្រូនិច សូមចុះឈ្មោះតាមរយៈវិបសាយ www.betterfactories.org/ilo
សម្រាប់ចម្ងល់ផ្សេងៗ សូមទាក់ទងមកកាន់មន្ត្រីទំនាក់ទំនង តាមរយៈអ៊ីម៉ែល betterfactories@ilo.org


better factories Cambodia